## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខ** ......១៣៣ ប្រ.ក


នាយកដ្ឋានមុខងារ និងធនធាន
ចូល លេខ: ៥៥២
ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៩
បញ្ជូន:


# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងបណ្ណាគារ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក. ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសរួមលេខ៦៥៧ សហវ.ប្រក. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១**.-

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងបណ្ណាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២**.-

ប្រកាសនេះ មានគោលដៅកំណត់អំពីប្រភេទនិងបទដ្ឋានកំណត់ទំហំ ការកំណត់សេវារដ្ឋបាល របបរាយការណ៍ ការហាមឃាត់ ការបញ្ឈប់អាជីវកម្ម និងការអនុញ្ញាតឱ្យបើកអាជីវកម្មឡើងវិញ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាកម្មបណ្ណាគារ។

**ប្រការ៣**.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបណ្ណាគារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤**.-

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- បណ្ណាគារ សំដៅដល់អគារ ឬ ផ្ទះលក់និងទិញសៀវភៅអានគ្រប់ប្រភេទ ឯកសារផ្សេងៗស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងអប់រំ ឯកសារជាឌីជីថល សម្ភារៈសិក្សា និងសម្ភារៈការិយាល័យ។

## ជំពូកទី២

## ប្រភេទនិងបទដ្ឋានកំណត់ទំហំបណ្ណាគារ

**ប្រការ៥**.-

បណ្ណាគារ ត្រូវបានបែងចែកជា២(ពីរ)៖

១- បណ្ណាគារខ្នាតតូច សំដៅដល់បណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ (ហាសិប) ម៉ែត្រការ៉េ។

២- បណ្ណាគារខ្នាតធំ សំដៅដល់បណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ (ហាសិប) ម៉ែត្រការ៉េឡើង។

**ប្រការ៦**.-

បទដ្ឋានវាស់វែងទំហំបណ្ណាគារ ត្រូវគណនាតាមមាត្រដ្ឋានរូបមន្តគណិតវិទ្យា។

បទដ្ឋានវាស់វែងទំហំបណ្ណាគារ ត្រូវគណនាទំហំនៃជាន់នីមួយៗនៃអគារ ឬ ផ្ទះដែលដាក់តាំងសៀវភៅអានគ្រប់ប្រភេទ ឯកសារផ្សេងៗស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងអប់រំ ឯកសារជាឌីជីថល សម្ភារៈសិក្សា និងសម្ភារៈការិយាល័យសម្រាប់អតិថិជនទិញ ឬ លក់។

## ជំពូកទី៣

## នីតិវិធីនៃការដាក់ពាក្យស្នើសុំ និង ការកំណត់កម្រៃសេវារដ្ឋបាល

**ប្រការ៧**.-

ការដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាតអាជីវកម្មបណ្ណាគារ ត្រូវបានអនុវត្តតាមសេចក្តីណែនាំស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីនិងទម្រង់បែបបទនៃការគ្រប់គ្រងបណ្ណាគារ។

**ប្រការ៨**.-

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០(ហាសិប)ម៉ែត្រការ៉េ និង បណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០(ហាសិប)ម៉ែត្រការ៉េឡើងត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៤
## របាយការណ៍

**ប្រការ៩.-**

បុគ្គលិកជួរក្រោយប្រចកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់លើការផ្តល់បណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារមកមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត។

## ជំពូកទី៥
## ការហាមឃាត់ ការបញ្ឈប់អាជីវកម្ម និងការអនុញ្ញាតឱ្យបើកអាជីវកម្មឡើងវិញ

**ប្រការ១០.-**

ត្រូវបានហាមឃាត់ដាច់ខាតការធ្វើអាជីវកម្មវត្ថុបុរាណ ផលិតផលទាំងឡាយណាដែលរំលោភបំពានលើស្នាដៃសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ប្រាសចាកពីសីលធម៌សង្គម ប៉ះពាល់អង្គព្រះមហាក្សត្រ រើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ភាសា ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដីឯករាជ្យជាតិ សន្តិភាព អធិបតេយ្យជាតិ និងសន្តិសុខជាតិ។

**ប្រការ១១.-**

ករណីរកឃើញថា ម្ចាស់បណ្ណាគារធ្វើអាជីវកម្មនូវផលិតផលដែលបានហាមឃាត់ដូចចែងក្នុងប្រការ១០ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចុះដល់ទីតាំងបណ្ណាគារដើម្បីដកហូតនិងរក្សាទុកផលិតផលទាំងនោះ ព្រមទាំងផ្អាកអាជីវកម្មជាបណ្តោះអាសន្ន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុនិងកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បណ្ណាគារ ដើម្បីបញ្ឈប់ការធ្វើអាជីវកម្មផលិតផលដែលបានហាមឃាត់។

គំរូកិច្ចសន្យាបញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់ មានជូនភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី១និងទី២នៃប្រកាសនេះ។

**ប្រការ១២.-**

បន្ទាប់ពីម្ចាស់បណ្ណាគារ បានធានាអះអាងនិងធ្វើកិច្ចសន្យាបញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់ ម្ចាស់បណ្ណាគារអាចប្រកបអាជីវកម្មឡើងវិញ។

**ប្រការ១៣.-**

ក្នុងករណីម្ចាស់បណ្ណាគារនៅតែបន្តការធ្វើអាជីវកម្មផលិតផលដែលបានហាមឃាត់ទាំងនោះទៀត មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន ដោយមានការឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីបញ្ឈប់អាជីវកម្មជាផ្លូវការ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា អគ្គនាយកនៃ

អគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត និងបុគ្គលិកច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ កើត ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង-សកុណា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានគ.ជ.អ.ប. នៃក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អង្គភាពនិងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  "ដើម្បីជូនជ្រាប"
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

(ឧបសម្ព័ន្ធទី១)

# គំរូកិច្ចសន្យា
# បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ........................................ ជាអក្សរឡាតាំង .................................... ភេទ ............ ថ្ងៃខែឆ្នាំកំណើត ...................... សញ្ជាតិ ............... អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ................................ តួនាទី(ម្ចាស់ ឬ អ្នកគ្រប់គ្រងអាជីវកម្ម) .............................. ប្រកបអាជីវកម្មបណ្ណាគារ ឈ្មោះ (ខ្មែរនិងឡាតាំង) ........................................................................................................................ ទូរសព្ទ ................................. អ៊ីម៉ែល ........................................................។

**សូមគោរពជូន**
**លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
........................................................

**កម្មវត្ថុ** ៖ បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់ .............................. ។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ បន្ទាប់ពីទទួលបានការណែនាំជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ចរួចមក ខ្ញុំបាទ-នាងខ្ញុំសូមធ្វើការអះអាងថានឹងបញ្ឈប់រាល់ការលក់ផលិតផលដែលបានហាមឃាត់ផ្ទុយនឹងច្បាប់ដែលបានកំណត់ជាធរមាន។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេចដោយសេចក្ដីអនុគ្រោះ។

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ............................ ខែ............... ឆ្នាំ............................ព.ស. ............

ថ្ងៃទី............... ខែ..................... ឆ្នាំ...............

ស្នាមមេដៃស្ដាំ និង ឈ្មោះអ្នកស្នើសុំ

( ឧបសម្ព័ន្ធទី២ )

# គំរូកិច្ចសន្យា
# បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ………………………………… ជាអក្សរឡាតាំង ……………………………… ភេទ ……….. ថ្ងៃខែឆ្នាំកំណើត ………………… សញ្ជាតិ ………….. អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ………………………… តួនាទី(ម្ចាស់ ឬ អ្នកគ្រប់គ្រងអាជីវកម្ម) ……………………… ប្រកបអាជីវកម្មបណ្ណាគារឈ្មោះ (ខ្មែរនិងឡាតាំង) ……………………………………………………………………………… ទូរសព្ទ …………………………… អ៊ីម៉ែល …………………………………………………។

**សូមគោរពជូន**
**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

……………………………………………………

**កម្មវត្ថុ** ៖ បញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់ ……………………….. ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា៖ បន្ទាប់ពីទទួលបានការណែនាំជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ចរួចមក ខ្ញុំបាទ-នាងខ្ញុំសូមធ្វើការអះអាងថានឹងបញ្ឈប់ការលក់ផលិតផលដែលបានហាមឃាត់ផ្ទុយនឹងច្បាប់ដែលបានកំណត់ជាធរមាន។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ……………………… ខែ…………. ឆ្នាំ……………………… ព.ស. ……….

ថ្ងៃទី…………… ខែ………………. ឆ្នាំ…………..

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខ** ៣៧០ វ.វ.ណា

# សេចក្តីណែនាំ

# ស្តីពី

# ការដាក់ឱ្យអនុវត្តនីតិវិធីនិងទម្រង់បែបបទនៃការគ្រប់គ្រងបណ្ណាគារ

ក្នុងគោលបំណងអនុវត្តអនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ស្របតាមប្រកាសលេខ១៣៣៧ ប្រ.ក. ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីការគ្រប់គ្រងបណ្ណាគារ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមធ្វើការណែនាំដូចខាងក្រោម៖

**ក. ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

១- រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបអាជីវកម្មលើសេវាកម្មបណ្ណាគារត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតមកអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត តាមគំរូពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ។

២- បុគ្គលិកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវចុះពិនិត្យដល់ទីតាំងសេវាកម្មដើម្បីកំណត់ទំហំបណ្ណាគារ មុននឹងផ្តល់យោបល់បច្ចេកទេសជូនប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីដាក់ជូនអភិបាលរាជធានី ខេត្ត ពិនិត្យសម្រេច។

៣- រដ្ឋបាលរាជធានី ខេត្ត មានសិទ្ធិចេញបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើង តាមរយៈអង្គភាពច្រកចេញចូលតែមួយ។

៤- បណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ ត្រូវដាក់បង្ហាញជាសាធារណៈដើម្បីងាយស្រួលដល់ការអនុវត្តការងារនិងត្រួតពិនិត្យរបស់មន្ត្រីជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

៥- បុគ្គលិកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវជំរុញដល់ម្ចាស់អាជីវកម្មឱ្យមកទទួលសេវាកម្មរដ្ឋបាលនេះជារៀងរាល់ឆ្នាំ តាមរយៈយន្តការច្រកចេញចូលតែមួយដែលមានជាធរមាន។ ករណីម្ចាស់បណ្ណាគារមិនព្រមមកទទួលសេវារដ្ឋបាល បុគ្គលិកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវដាក់លិខិតអញ្ជើញដោយទុករយៈពេល១៥ថ្ងៃ ក្រោយទទួលបានការឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ គំរូលិខិតអញ្ជើញ មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ។

៦- ករណីម្ចាស់បណ្ណាគារមិនព្រមមកទទួលសេវារដ្ឋបាលតាមរយៈលិខិតអញ្ជើញ បុគ្គលិកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវស្នើសុំការសហការជាមួយអាជ្ញាធរមាន

សមត្ថកិច្ចដើម្បីផ្អាកអាជីវកម្មបណ្តោះអាសន្ន ក្រោយទទួលបានការឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ គំរូលិខិតផ្អាកអាជីវកម្មបណ្តោះអាសន្ន មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ។

៧- កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើងត្រូវអនុវត្តតាមប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ខ. ការផ្តល់សេវារដ្ឋបាលតាមរយៈការិយាល័យច្រកចេញចូលតែមួយ

១- រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបអាជីវកម្មលើសេវាកម្មបណ្ណាគារត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតមកការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមគំរូពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២នៃសេចក្តីណែនាំនេះ។

២- បុគ្គលិកជួរក្រោយនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យដល់ទីតាំងសេវាកម្មដើម្បីកំណត់ទំហំបណ្ណាគារ មុននឹងផ្តល់យោបល់បច្ចេកទេសជូនប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យសម្រេច។

៣- រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិចេញបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម ៥០ម៉ែត្រការ៉េ តាមរយៈការិយាល័យច្រកចេញចូលតែមួយ។

៤- បណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ ត្រូវដាក់បង្ហាញជាសាធារណៈដើម្បីងាយស្រួលដល់ការអនុវត្តការងារនិងត្រួតពិនិត្យរបស់មន្ត្រីជួរក្រោយនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៥- បុគ្គលិកជួរក្រោយនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវជំរុញដល់ម្ចាស់អាជីវកម្មឱ្យមកទទួលសេវាកម្មរដ្ឋបាលនេះជារៀងរាល់ឆ្នាំ តាមរយៈយន្តការច្រកចេញចូលតែមួយដែលមានជាធរមាន។ ករណីម្ចាស់បណ្ណាគារមិនព្រមមកទទួលសេវារដ្ឋបាល បុគ្គលិកជួរក្រោយនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់លិខិតអញ្ជើញដោយទុករយៈពេល១៥ថ្ងៃក្រោយទទួលបានការឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ គំរូលិខិតអញ្ជើញមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី២នៃសេចក្តីណែនាំនេះ។

៦- ករណីម្ចាស់បណ្ណាគារមិនព្រមមកទទួលសេវារដ្ឋបាលតាមរយៈលិខិតអញ្ជើញ បុគ្គលិកជួរក្រោយនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីផ្អាកអាជីវកម្មបណ្តោះអាសន្ន ក្រោយទទួលបានការឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ គំរូលិខិតផ្អាកអាជីវកម្មបណ្តោះអាសន្ន មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី២នៃសេចក្តីណែនាំនេះ។

៧- កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ ត្រូវអនុវត្តតាមប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ទទួលបានសេចក្ដីណែនាំខាងលើ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត និងបុគ្គលិកច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.ចន្ទ..១២កើត...ខែ.ស្រាពណ៍.. ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២......... ខែ.សីហា...... ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង-សកុណា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានគ.ជ.អ.ប. នៃក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ "ដើម្បីជូនជ្រាប"
- អង្គភាពនិងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ "ដើម្បីអនុវត្ត"
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីសហការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

(ឧបសម្ព័ន្ធទី១)

# ពាក្យស្នើសុំ
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបើកអាជីវកម្ម
# បណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
# បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើង

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ....................................... អក្សរឡាតាំង ...............................................
ភេទ...........ថ្ងៃខែឆ្នាំកំណើត............................. សញ្ជាតិ ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ........
ផ្លូវ...........ភូមិ ..................... ឃុំ/សង្កាត់ ...........................ក្រុង/ស្រុក/ខណ្ឌ ......................................
រាជធានី/ខេត្ត ............................. អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ .........................................
លេខទូរសព្ទទំនាក់ទំនង ..........................................ជាម្ចាស់/តំណាង..............................................។

## សូមគោរពជូន
## ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

.......................................................

**កម្មវត្ថុ** ៖ សំណើសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសុំការផ្តល់អាជ្ញាប័ណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ ដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ ..................................... ជាអក្សរឡាតាំង ....................................
- អាសយដ្ឋាន ...............................................................................................................
- ទូរស័ព្ទ ............................................. អ៊ីម៉ែល .........................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ.......................... ខែ.............. ឆ្នាំ.......................... ព.ស. ............

ថ្ងៃទី.............. ខែ.................... ឆ្នាំ..............

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ (បន្ត)
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
# បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើង

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ………………………………… អក្សរឡាតាំង ………………………………………
ភេទ…………ថ្ងៃខែឆ្នាំកំណើត………………………… សញ្ជាតិ ……………… អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ………
ផ្លូវ…………ភូមិ ………………… ឃុំ/សង្កាត់ ……………………… ក្រុង/ស្រុក/ខណ្ឌ ……………………………………
រាជធានី/ខេត្ត ………………………… អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ……………………………………
លេខទូរសព្ទទំនាក់ទំនង ……………………………………… ជាម្ចាស់/តំណាង………………………………………។

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

…………………………………………………

**កម្មវត្ថុ ៖** សំណើសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបន្តអាជីវកម្មបណ្ណាគារ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសុំការផ្តល់អាជ្ញាប័ណ្ណអនុញ្ញាតបន្តអាជីវកម្មបណ្ណាគារដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ …………………………………… ជាអក្សរឡាតាំង ……………………………………
- អាសយដ្ឋាន ……………………………………………………………………………………………………
- ទូរស័ព្ទ …………………………………………… អ៊ីម៉ែល …………………………………………………។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ………………………… ខែ………… ឆ្នាំ……………………… ព.ស. …………

ថ្ងៃទី……………ខែ………………… ឆ្នាំ……………

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
## សុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
## បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើង

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ........................................ ជាអក្សរឡាតាំង ...................................... ភេទ ............ ថ្ងៃខែឆ្នាំកំណើត ........................ សញ្ជាតិ ............... តួនាទី(ម្ចាស់ ឬ អ្នកគ្រប់គ្រងអាជីវកម្ម) ................................ ប្រកបអាជីវកម្មបណ្ណាគារឈ្មោះ (ខ្មែរនិងឡាតាំង) ................................................... ............................................... ទូរសព្ទ .................................... អ៊ីម៉ែល ឬ វេបសាយ .........................។

### សូមធ្វើកិច្ចសន្យាដូចខាងក្រោម៖

១- ជានាគោរពគោលការណ៍និងបទប្បញ្ញត្តិច្បាប់របស់រដ្ឋ

២- ជានាគោរពគោលការណ៍ណែនាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង រដ្ឋបាលរាជធានី ខេត្ត

៣- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់

៤- ជានាមិនធ្វើអាជីវកម្មលើសៀវភៅ ឬ ឯកសារដែលគ្មានការអនុញ្ញាត

៥- ទទួលខុសត្រូវចំពោះមុខច្បាប់រាល់ការធ្វើអាជីវកម្មវត្ថុបុរាណ ឬ ធ្វើអាជីវកម្មសៀវភៅ ឬ ឯកសារដែលប្រាសចាកសីលធម៌សង្គម ប៉ះពាល់អង្គព្រះមហាក្សត្រ រើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ភាសា ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ សន្តិភាព អធិបតេយ្យជាតិ និងសន្តិសុខជាតិ

៦- ករណីទីតាំងអាជីវកម្មខ្ញុំមានតាំងលក់សម្ភារៈ ឬ បរិក្ខានានាដែលត្រូវស្នើសុំលិខិតអនុញ្ញាត ឬ បណ្ណអនុញ្ញាតក្នុងវិស័យជំនាញដទៃទៀត ខ្ញុំនឹងអនុវត្តតាមលិខិតបទដ្ឋានជាធរមានក្នុងវិស័យនោះ

៧- អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិផ្អាកជាបណ្តោះអាសន្ន ឬ បញ្ឈប់ជាផ្លូវការរាល់ការធ្វើអាជីវកម្មណាដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ.............................. ខែ............... ឆ្នាំ............................ព.ស. ............

ថ្ងៃទី............... ខែ.................... ឆ្នាំ...............

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតបញ្ជាក់ទីតាំង

របស់ឈ្មោះ ..........................................ឈ្មោះអាជីវកម្ម ..........................................
អាសយដ្ឋាន ផ្ទះលេខ ...........ផ្លូវ ...............ភូមិ ...............ឃុំ/សង្កាត់ ......................ក្រុង/ស្រុក/ខណ្ឌ
............................រាជធានី/ខេត្ត ..............................ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

<u>គំនូសបំព្រួញបង្ហាញទីតាំង</u>

ថ្ងៃ......................... ខែ............. ឆ្នាំ......................ព.ស. ...........
ថ្ងៃទី.............ខែ.................. ឆ្នាំ.............
ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

លេខ: ..................
បានឃើញនិងបញ្ជាក់
គំនូសបំព្រួញទីតាំងនេះពិតជាត្រឹមត្រូវប្រាកដមែន
ថ្ងៃទី.............ខែ.................. ឆ្នាំ.............
ហត្ថលេខាមេឃុំ/ចៅសង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ………………………………
**លេខ** ……………………… ថ្ងៃ……………………… ខែ………… ឆ្នាំ……………………… ព.ស. …………
………………………ថ្ងៃទី…………ខែ……………ឆ្នាំ…………

# លិខិតអញ្ជើញ
# លោក លោកស្រី ម្ចាស់អាជីវកម្មបណ្ណាគារ

………………………………………………………………………

**កម្មវត្ថុ ៖** ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ

**យោង ៖**
- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ រដ្ឋបាលរាជធានី/ខេត្ត …………………… ………… សូមអញ្ជើញលោក លោកស្រីម្ចាស់អាជីវកម្មបណ្ណាគារដែលមានអាសយដ្ឋានផ្ទះលេខ ………… ផ្លូវ ……………… ឃុំ/សង្កាត់ ……………… ក្រុង/ស្រុក/ខណ្ឌ ……………… រាជធានី/ខេត្ត …………… មកកាន់អង្គភាពច្រកចេញចូលតែមួយ ដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ នៅរៀងរាល់ម៉ោងធ្វើការក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតនេះ។

ជាមួយគ្នានេះ រដ្ឋបាលរាជធានី/ខេត្ត ……………………………សូមជម្រាបជូនលោក លោកស្រីម្ចាស់អាជីវកម្មជ្រាបថា ការខកខានមិនបានបំពេញកាតព្វកិច្ចដូចដែលបានបញ្ញត្តក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន រដ្ឋបាលរាជធានី/ខេត្ត ………………………… នឹងចាត់វិធានការផ្អាកអាជីវកម្មជាបណ្តោះអាសន្ន ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

រដ្ឋបាលរាជធានី/ខេត្ត ……………………………………សង្ឃឹមនិងជឿជាក់ថា លោក លោកស្រីម្ចាស់អាជីវកម្មបណ្ណាគារ នឹងអញ្ជើញមកតាមពេលវេលាកំណត់កុំបីខកខាន។

សូមលោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**………………………

ចម្លងជូន៖
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីជូនជ្រាប"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………….
**លេខ** ………………………….

ថ្ងៃ……………………….. ខែ…………… ឆ្នាំ………………………..ព.ស. ………..
……………………….ថ្ងៃទី………….ខែ……………. ឆ្នាំ…………..

**ជម្រាបមក**
**លោក លោកស្រី ម្ចាស់អាជីវកម្មបណ្ណាគារ**
………………………………………………………………………………

**កម្មវត្ថុ ៖** ស្តីពីការផ្អាកជាបណ្តោះអាសន្នការប្រកបអាជីវកម្មបណ្ណាគារករណីល្មើសនឹងកាតព្វកិច្ច
**យោង ៖** – ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
– លិខិតអញ្ជើញលេខ……………. ចុះថ្ងៃទី…………. ខែ……………. ឆ្នាំ………………. ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក លោកស្រីម្ចាស់បណ្ណាគារ ………………………………….ដែលមានអាសយដ្ឋាន ផ្ទះលេខ ……….. ផ្លូវ ……………..ឃុំ/សង្កាត់ ……………….. ក្រុង/ស្រុក/ខណ្ឌ ………………..រាជធានី/ខេត្ត ……………. ជ្រាបថា៖ រដ្ឋបាលរាជធានី ខេត្ត ……………………………. បានពិនិត្យឃើញលោក លោកស្រីម្ចាស់បណ្ណាគារមិនសហការជាមួយក្រុមការងាររបស់អង្គភាពច្រកចេញចូលតែមួយដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារតាមបញ្ញត្តិច្បាប់ដែលមានជាធរមាន ដូច្នេះរដ្ឋបាលរាជធានី ខេត្ត សូមផ្អាកនូវអាជីវកម្មនេះជាបណ្តោះអាសន្នចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីម្ចាស់បណ្ណាគារ ជ្រាបនិងអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូម លោក លោកស្រីម្ចាស់បណ្ណាគារ ទទួលនូវការអោប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**……………………….

ចម្លងជូន៖
- ស្នងការនគរបាលរាជធានី ខេត្ត
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីសហការ"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល**..................................
លេខ : ..............................

## បណ្ណអនុញ្ញាត
## សេវាកម្មបណ្ណាគារ

យោង ៖ – អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អនុញ្ញាតឲ្យលោក–លោកស្រី :.............................. ភេទ ................ ថ្ងៃខែឆ្នាំកំណើត......................

ប្រភេទសេវាកម្ម : បើកអាជីវកម្មបណ្ណាគារ (បន្ត)

អាសយដ្ឋានអាជីវកម្ម : ផ្ទះលេខ .......... ផ្លូវលេខ ............ ឃុំ/សង្កាត់.................. ក្រុង/ស្រុក/ខណ្ឌ ..................

នាមករណ៍ :..........................................................

បណ្ណអនុញ្ញាតសេវាកម្មនេះមានសុពលភាពត្រឹមថ្ងៃទី.................. ខែ.................. ឆ្នាំ..................

មុនផុតកំណត់រយៈពេល១៥ថ្ងៃ អាជីវករត្រូវយកបណ្ណអនុញ្ញាតនេះ មកប្តូរដើម្បីដាក់សុំបន្តអាជីវកម្មនៅឆ្នាំបន្ទាប់។

ថ្ងៃ......................... ខែ............ ឆ្នាំ.......................... ព.ស. ...........

......................... ថ្ងៃទី............ ខែ.............. ឆ្នាំ............

**អភិបាល**.........................

បញ្ជាក់៖ បណ្ណអនុញ្ញាតនេះត្រូវដាក់តាំង ឬព្យួរនៅកន្លែងទទួលភ្ញៀវ

( ឧបសម្ព័ន្ធទី២ )

# ពាក្យស្នើសុំ
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបើកអាជីវកម្ម
# បណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
# បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ........................................ អក្សរឡាតាំង ................................................
ភេទ............ថ្ងៃខែឆ្នាំកំណើត................................ សញ្ជាតិ ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ .........
ផ្លូវ............ភូមិ ...................... ឃុំ/សង្កាត់ ............................ក្រុង/ស្រុក/ខណ្ឌ ........................................
រាជធានី/ខេត្ត ............................. អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ........................................
លេខទូរសព្ទទំនាក់ទំនង ............................................ជាម្ចាស់/តំណាង..........................................។

## សូមគោរពជូន
## លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

........................................................................................

**កម្មវត្ថុ** ៖ សំណើសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារ ដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ ................................. ជាអក្សរឡាតាំង ....................................
- អាសយដ្ឋាន ...........................................................................................................
- ទូរសព្ទ ........................................... អ៊ីម៉ែល ..........................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ............................ ខែ.............. ឆ្នាំ............................ព.ស. ............
ថ្ងៃទី..............ខែ..................... ឆ្នាំ...............
ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ (បន្ត)
# ការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
# បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ...................................... អក្សរឡាតាំង ..............................................
ភេទ............ថ្ងៃខែឆ្នាំកំណើត.............................. សញ្ជាតិ ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ .........
ផ្លូវ............ភូមិ .................... ឃុំ/សង្កាត់ ...........................ក្រុង/ស្រុក/ខណ្ឌ ........................................
រាជធានី/ខេត្ត ............................. អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ........................................
លេខទូរសព្ទទំនាក់ទំនង ..........................................ជាម្ចាស់/តំណាង.............................................។

**សូមគោរពជូន**
**លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
.......................................................................................

**កម្មវត្ថុ** ៖ សំណើសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបន្តអាជីវកម្មបណ្ណាគារ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ខ្ញុំបាទ-នាងខ្ញុំសុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាតបន្តអាជីវកម្មបណ្ណាគារ ដែលមាន៖

- នាមករណ៍ជាភាសាខ្មែរ ..................................... ជាអក្សរឡាតាំង ..................................
- អាសយដ្ឋាន ...........................................................................................................
- ទូរសព្ទ ........................................... អ៊ីម៉ែល ..................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

*សូមជូនភ្ជាប់មកជាមួយ៖*

| | |
|---|---|
| ១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ២- វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម (ថតចម្លងដោយនីត្យានុកូលកម្ម) | ១ច្បាប់ |
| ៣- រូបថតបច្ចុប្បន្នទំហំ៤x៦ | ៣សន្លឹក |
| ៤- កិច្ចសន្យា | ១ច្បាប់ |
| ៥- ប្លង់គំនូសបង្ហាញទីតាំង | ១ច្បាប់ |

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ........................... ខែ.............. ឆ្នាំ...........................ព.ស. ............
ថ្ងៃទី..............ខែ.................... ឆ្នាំ...............
ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
## សុំការផ្តល់អាជ្ញាបណ្ណអនុញ្ញាត
## បើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ........................................ ជាអក្សរឡាតាំង ....................................
ភេទ ............ ថ្ងៃខែឆ្នាំកំណើត ...................... សញ្ជាតិ .............. តួនាទី(ម្ចាស់ ឬ អ្នកគ្រប់គ្រងអាជីវកម្ម)
............................... ប្រកបអាជីវកម្មបណ្ណាគារឈ្មោះ (ខ្មែរនិងឡាតាំង) ..............................................
.............................................. ទូរសព្ទ ................................ អ៊ីម៉ែល ឬ វេបសាយ .........................។

## សូមធ្វើកិច្ចសន្យាដូចខាងក្រោម៖

១- ជានាគោរពគោលការណ៍និងបទប្បញ្ញត្តិច្បាប់របស់រដ្ឋ

២- ជានាគោរពគោលការណ៍ណែនាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង រដ្ឋបាលក្រុង ស្រុក ខណ្ឌ

៣- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់

៤- ជានាមិនធ្វើអាជីវកម្មលើសៀវភៅ ឬ ឯកសារដែលគ្មានការអនុញ្ញាត

៥- ទទួលខុសត្រូវចំពោះមុខច្បាប់រាល់ការធ្វើអាជីវកម្មវត្ថុបុរាណ ឬ ធ្វើអាជីវកម្មសៀវភៅ ឬ ឯកសារដែលប្រាសចាកសីលធម៌សង្គម ប៉ះពាល់អង្គព្រះមហាក្សត្រ រើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ភាសា ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ សន្តិភាព អធិបតេយ្យជាតិ និងសន្តិសុខជាតិ

៦- ករណីទីតាំងអាជីវកម្មខ្ញុំមានតាំងលក់សម្ភារៈ ឬ បរិក្ខានានាដែលត្រូវស្នើសុំលិខិតអនុញ្ញាត ឬ បណ្ណអនុញ្ញាតក្នុងវិស័យជំនាញដទៃទៀត ខ្ញុំនឹងអនុវត្តតាមលិខិតបទដ្ឋានជាធរមានក្នុងវិស័យនោះ

៧- អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិផ្អាកជាបណ្តោះអាសន្ន ឬ បញ្ឈប់ជាផ្លូវការរាល់ការធ្វើអាជីវកម្មណាដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ............................ ខែ.............. ឆ្នាំ.............................ព.ស. ............
ថ្ងៃទី..............ខែ.................... ឆ្នាំ..............
**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតបញ្ជាក់ទីតាំង

របស់ឈ្មោះ ..............................................ឈ្មោះអាជីវកម្ម ..............................................

អាសយដ្ឋាន ផ្ទះលេខ ............ផ្លូវ ..................ភូមិ ..................ឃុំ/សង្កាត់ ..........................ក្រុង/ស្រុក/ខណ្ឌ ............................... រាជធានី/ខេត្ត ................................. ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

<u>គំនូសបំព្រួញបង្ហាញទីតាំង</u>

ថ្ងៃ............................ ខែ.............. ឆ្នាំ..........................ព.ស. ...........

ថ្ងៃទី..............ខែ.................... ឆ្នាំ...............

ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

លេខ: ........................

បានឃើញនិងបញ្ជាក់

គំនូសបំព្រួញទីតាំងនេះពិតជាត្រឹមត្រូវប្រាកដមែន។

ថ្ងៃទី..............ខែ.................... ឆ្នាំ..............

ហត្ថលេខាមេឃុំ/ចៅសង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………

**លេខ** ……………………… ថ្ងៃ……………………… ខែ………… ឆ្នាំ………………………ព.ស. …………

……………………………ថ្ងៃទី………… ខែ……………… ឆ្នាំ……………

# លិខិតអញ្ជើញ
# លោក លោកស្រី ម្ចាស់អាជីវកម្មបណ្ណាគារ

………………………………………………………………………………

**កម្មវត្ថុ ៖** ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ

**យោង ៖** – អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– ប្រកាសរួមលេខ២៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ …………………… ………… សូមអញ្ជើញលោក លោកស្រីម្ចាស់អាជីវកម្មបណ្ណាគារដែលមានអាសយដ្ឋានផ្ទះលេខ ………… ផ្លូវ ……………… ឃុំ/សង្កាត់ ……………… ក្រុង/ស្រុក/ខណ្ឌ ……………… រាជធានី/ខេត្ត …………… មកកាន់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ នៅរៀងរាល់ម៉ោងធ្វើការក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតនេះ។

ជាមួយគ្នានេះ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ………………… សូមជម្រាបជូនលោក លោកស្រីម្ចាស់អាជីវកម្មជ្រាបថា ការខកខានមិនបានបំពេញកាតព្វកិច្ចដូចដែលបានបញ្ញត្តក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ………………… នឹងចាត់វិធានការផ្អាកអាជីវកម្មជាបណ្តោះអាសន្នស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ …………………………សង្ឃឹមនិងជឿជាក់ថា លោក លោកស្រីម្ចាស់អាជីវកម្មបណ្ណាគារ នឹងអញ្ជើញមកតាមពេលវេលាកំណត់កុំបីខកខាន។

សូមលោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**………………………

ចម្លងជូន៖
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីជូនជ្រាប"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………….
**លេខ** ………………………..                    ថ្ងៃ…………………….. ខែ………… ឆ្នាំ……………………..ព.ស. ………..
…………………………ថ្ងៃទី……………ខែ……………… ឆ្នាំ……………

**ជម្រាបមក**
**លោក លោកស្រី ម្ចាស់អាជីវកម្មបណ្ណាគារ**
……………………………………………………………………………………

**កម្មវត្ថុ ៖** ស្តីពីការផ្អាកជាបណ្តោះអាសន្នការប្រកបអាជីវកម្មបណ្ណាគារករណីល្មើសនឹងកាតព្វកិច្ច

**យោង ៖** – ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
– លិខិតអញ្ជើញលេខ……………. ចុះថ្ងៃទី………… ខែ…………… ឆ្នាំ……………… ស្តីពីការបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក លោកស្រីម្ចាស់បណ្ណាគារ …………………………………ដែលមានអាសយដ្ឋាន ផ្ទះលេខ ……….. ផ្លូវ ……………..ឃុំ/សង្កាត់ ……………….. ក្រុង/ស្រុក/ខណ្ឌ ………………. រាជធានី/ខេត្ត …………… ជ្រាបថា៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ……………………………… បានពិនិត្យឃើញលោក លោកស្រីម្ចាស់បណ្ណាគារមិនសហការជាមួយក្រុមការងាររបស់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញកាតព្វកិច្ចបង់កម្រៃសេវាកម្មបណ្ណាគារតាមបញ្ញត្តិច្បាប់ដែលមានជាធរមាន ដូច្នេះរដ្ឋបាលក្រុង ស្រុក ខណ្ឌ សូមផ្អាកនូវអាជីវកម្មនេះជាបណ្តោះអាសន្នចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីម្ចាស់បណ្ណាគារ ជ្រាបនិងអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូម លោក លោកស្រីម្ចាស់បណ្ណាគារ ទទួលនូវការអោប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អភិបាល**………………………

ចម្លងជូន៖
- អធិការដ្ឋានក្រុង ស្រុក ខណ្ឌ
- មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត "ដើម្បីសហការ"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល**..............................
លេខ : ..............................

# បណ្ណអនុញ្ញាត
## សេវាកម្មបណ្ណាគារ

យោង ៖
– អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
– ប្រកាសរួមលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អនុញ្ញាតឲ្យលោក–លោកស្រី : .............................. ភេទ .............. ថ្ងៃខែឆ្នាំកំណើត..............................
ប្រភេទសេវាកម្ម : បើកអាជីវកម្មបណ្ណាគារ (បន្ត)
អាសយដ្ឋានអាជីវកម្ម : ផ្ទះលេខ .......... ផ្លូវលេខ .......... ឃុំ/សង្កាត់.............. ក្រុង/ស្រុក/ខណ្ឌ ..............
នាមករណ៍ : ..............................
បណ្ណអនុញ្ញាតសេវាកម្មនេះមានសុពលភាពត្រឹមថ្ងៃទី.............. ខែ.............. ឆ្នាំ..............

មុនផុតកំណត់រយៈពេល១៥ថ្ងៃ អាជីវករត្រូវយកបណ្ណអនុញ្ញាតនេះ មកប្តូរដើម្បីដាក់សុំបន្តអាជីវកម្មនៅឆ្នាំបន្ទាប់។

ថ្ងៃ.............. ខែ.............. ឆ្នាំ.............. ព.ស. ..........
.............. ថ្ងៃទី.......... ខែ.......... ឆ្នាំ..........
**អភិបាល**..............................

បញ្ជាក់៖ បណ្ណអនុញ្ញាតនេះត្រូវដាក់តាំង ឬ ព្យួរនៅកន្លែងទទួលភ្ញៀវ